ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

≡ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស
អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
ក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ និងអន្តរជាតិ
លេខ.........................................

# របាយការណ៍

## បូកសរុបលទ្ធផលការងារប្រចាំខែកក្កដា ឆ្នាំ២០២២

### ក-អំពីកម្លាំង៖

សរុបបួមចំនួន៖ ០៥នាក់ (ស្រី០២នាក់) អវត្តមាន៖ ០០

### ខ-សកម្មភាព និងលទ្ធផលការងារ

ខ.១-កិច្ចប្រជុំពង្រឹងកិច្ចសហប្រតិបត្តិការ ការកសាងគោលនយោបាយ និងបទដ្ឋានគតិយុត្តិនានា

<u>សកម្មភាពក្នុងស្រុក</u>

- **ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២២** លោកឧត្តមសេនីយ៍ត្រី អ៊ុន មាន ប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ និងអន្តរជាតិ និងជាអនុប្រធានក្រុមការងារព័ត៌មានវិទ្យា នៃអគ្គលេខាធិការដ្ឋាន គជបជ បានបើកវគ្គបណ្តុះបណ្តាលអក្ខរកម្មឌីជីថលស្តីពី៖ មូលដ្ឋានគ្រឹះនៃការសរសេរកូដកម្មវិធី ជូនដល់ក្រុមជំនួយកិច្ចការទាំង៧ ដែលជាក្រុមការងារព័ត៌មានវិទ្យាថ្មី ដែលបានជ្រើសរើសមាសភាពចេញពី ក្រុមជំនួយកិច្ចការទាំង៦ និងលេខាធិការដ្ឋាន ក្នុងគោលបំណងដើម្បីពង្រឹងសមត្ថភាពដល់មន្ត្រីក្រោមឱវាទ នៃអគ្គលេខាធិការដ្ឋាន គជបជ។ គួររំលឹកផងដែលថា វគ្គបណ្តុះបណ្តាលជំនាញនេះធ្វើឡើងរយៈពេល៣ខែ ដែលសិក្សារៀងរាល់ព្រឹកថ្ងៃព្រហស្បតិ៍ និងសុក្រនូវរាល់សប្តាហ៍នៃខែនីមួយៗ។ សមាសភាពចូលរួមមាន លោកឧត្តមសេនីយ៍ត្រី អ៊ុន មាន ប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ និង អន្តរជាតិ និងជាអនុប្រធានក្រុមការងារ ព័ត៌មានវិទ្យា ជាគ្រូឧទ្ទេសក៍ លោកឧត្តមសេនីយ៍ត្រី យឹម សំណាង អនុប្រធានក្រុមជំនួយកិច្ចការយុត្តិធម៌ លោកវរសេនីយ៍ត្រី សោម ស៊ីវរិន លោកវរសេនីយ៍ត្រី ធន ដារ៉ារិទ្ធ លោកអនុសេនីយ៍ឯក រ៉េន សុភ័ក្រ្តបញ្ញា នាយរងការិយាល័យនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងលោកស្រីអនុសេនីយ៍ឯក ហោង សុបុទុម មន្ត្រីនៃក្រុមជំនួយកិច្ចការបង្ការទប់ស្កាត់ ដែលមានចំនួនសរុប ៧រូប (ស្រី០១)។

- **ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ែន សិរីលក្ខិណា អគ្គលេខាធិការរងក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ និងអន្តរជាតិបានអញ្ជើញចូលរួមកិច្ចប្រជុំត្រៀមបើកវគ្គបណ្តុះ បណ្តាលស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ដែលបានរៀបចំដោយអង្គការ ASEAN-ACT តាមរយៈប្រព័ន្ធវីដេអូអនឡាញ។ គោលបំណងនៃកិច្ចប្រជុំបានផ្តោតសំខាន់លើកិច្ចពិភាក្សាអំពីវគ្គបណ្តុះបណ្តាលស្តីពី ការកំណត់អត្តសញ្ញាណជនរងគ្រោះ ការបន្តកិច្ចប្រជុំ SOP ស្តីពីការសហការក្នុងការអនុវត្តច្បាប់រវាងកម្ពុជា-ថៃ និងបន្ត

ការប្រជុំពិនិត្យកែសម្រួលស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ។ អញ្ជើញចូលរួមក្នុងកម្មវិធីនេះមាន លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ លោកឧត្តមសេនីយឯក លី តុងហ៊ុយ អគ្គលេខាធិការរង ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ លោកឧត្តមសេនីយ៍ឯក យ៉ែម ចាន់ណារុំ អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ លោកឧត្តមសេនីយ៍ទោ កែវ សុវណ្ណា អគ្គលេខាធិការរង ក្រុមជំនួយកិច្ចបង្កាទប់ស្កាត់ លោកឧត្តមសេនីយ៍ទោ សេក ស៊ីវេត ប្រធានក្រុមជំនួយកិច្ចការ ការពារជនរងគ្រោះ លោកឧត្តមសេនីយ៍ត្រី តែ សុថារ៉េត អគ្គលេខាធិការរង ក្រុមជំនួយកិច្ចការយុត្តិធម៌ លោកឧត្តមសេនីយ៍ទោ រ៉ន សុភ័ក្រ្តវឌ្ឍនា ប្រធានក្រុមជំនួយកិច្ចការបង្កាទប់ស្កាត់ លោក ធន ដារ៉ារិទ្ធ នាយរងការិយាល័យ នៃ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងតំណាងអង្គការ ASEAN-ACT លោក ណៃ ឈួន ប្រធានអង្គការប្រចាំនៅ កម្ពុជា និងសហការី។

- **ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង បានចូលរួមកិច្ចប្រជុំពិភាក្សាតាមប្រព័ន្ធអនឡាញរវាង អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាមួយអង្គការ RATANAK International ស្តីពី "កិច្ចសហការសម្រាប់ការអនុវត្តគម្រោងបង្ការទប់ស្កាត់ភាពងាយរងគ្រោះនៃអំពើជួញដូរមនុស្ស" ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងមានការអញ្ជើញចូលរួមពី លោកជំទាវឧត្តមសេនីយ៍ឯក វេជ្ជ. ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ ឯកឧត្តមលោកជំទាវ អគ្គលេខាធិការរង និងប្រធានក្រុមជំនួយកិច្ចការទាំង៦ និងតំណាងអង្គការ RATANAK International សរុបចំនួន ២០នាក់។

- **ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរងទទួលបន្ទុកក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ និងអន្តរជាតិ និងជាសមាជិកក្រុមការងារ SOMTC និងជាមន្ត្រីបង្គោល ផែនការងារប្រឆាំងការជួញដូរមនុស្ស បានអញ្ជើញចូលរួមកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់អាស៊ានលើកទី១៨ ស្តីពីក្រុមការងារឧក្រិដ្ឋឆ្លងដែន ក្នុងកិច្ចការងារប្រឆាំងការជួញដូរមនុស្ស តាមរយៈប្រព័ន្ធវីដេអូពីចម្ងាយ។ គោលបំណងនៃកិច្ចប្រជុំ គឺដើម្បីធ្វើការផ្លាស់ប្តូរទស្សនៈលើនិន្នាការ ដែលកំពុងរីកចម្រើន ឱកាស និងដំណោះស្រាយលើបញ្ហាប្រឈមនានា ក្នុងការកំណត់នូវទម្រង់ផ្សេងៗ នៃការប្រឆាំងការជួញដូរមនុស្ស។ អញ្ជើញចូលរួមក្នុងកិច្ចប្រជុំនេះមានតំណាងក្រុមការងារកម្ពុជា គឺលោកជំទាវឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា ឯកឧត្តមឧត្តមសេនីយ៍ឯក សុខ រស្មី អនុប្រធាននាយកដ្ឋាន នៃនាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ និងជាសមាជិកក្រុមការងារ SOMTC កម្ពុជា និងឯកឧត្តម សរ ម៉ូលីនី អនុប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការនគរបាលជាតិ។

- **ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២២** លោកឧត្តមសេនីយ៍ត្រី អ៊ុន មាន ប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការ ជាតិ និងអន្តរជាតិ និងលោកស្រីវរសេនីយ៍ទោ ថោង សុវត្ថិ អនុប្រធានក្រុម បានអញ្ជើញចូលរួមកិច្ចប្រជុំ ពិភាក្សា អំពីកិច្ចសហប្រតិបត្តិការផ្លូវច្បាប់ ដើម្បីអនុវត្តពាក់ព័ន្ធនឹងករណីជួញដូរមនុស្សនៅ

ក្នុងតំបន់អាស៊ាន ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដោយមានការអញ្ជើញចូលរួមពី លោកជំទាវ ឧត្តមសេនីយ៍ឯក ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ លោកស្រី Rebecca Miller មានតួនាទីជា Regional Coordinator Human Trafficking and Migrant Smuggling (UNODC), លោកស្រី Marika Mc Adam មានតួនាទី International Law and Policy Advisor (ASEAN-ACT) ឯកឧត្តម ឧត្តមសេនីយ៍ទោ នី គឹមស្រេន ឯកឧត្តម ឧត្តមសេនីយ៍ត្រី តែ សុថារេត អគ្គលេខាធិការរង លោកឧត្តមសេនីយ៍ទោ ហាង ដឺវ័ន្ត ប្រធានលេខាធិការ លោកឧត្តមសេនីយ៍ទោ កែវ ផល្លា ប្រធានក្រុមការងារកិច្ចការយុត្តិធម៌ លោកឧត្តមសេនីយ៍ទោ ប៉ុណ្ណ ចន្ទា ប្រធានក្រុមការងារអនុវត្តច្បាប់ លោកឧត្តមសេនីយ៍ត្រី អ៊ុន មាន ប្រធានក្រុមការងារសហប្រតិបត្តិការអន្តរជាតិ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងក្រុមការងារពាក់ព័ន្ធមួយចំនួនទៀត សរុបចំនួន ១៥ រូប (ស្រី៥ រូប) ។

- **ថ្ងៃទី១៩ ដល់ ២១ ខែកក្កដា ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ែន សិរីលក្ខិណា អគ្គលេខាធិការរង ទទួលបន្ទុកក្រុមជំនួយកិច្ចការ សហប្រតិបត្តិការជាតិ និងអន្តរជាតិ និងជាសមាជិកក្រុមការងារ SOMTC និងជាមន្ត្រីបង្គោលផែនការងារប្រឆាំងការជួញដូរមនុស្ស បានអញ្ជើញចូលរួមកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់អាស៊ាន ទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែនលើកទី២២ និងកិច្ចប្រជុំពាក់ព័ន្ធដែលបានរៀបចំឡើងតាមប្រព័ន្ធវីដេអូពីចម្ងាយ។ កិច្ចប្រជុំនេះកម្ពុជាត្រូវបានធ្វើជាម្ចាស់ផ្ទះ ដែលបានដឹកនាំដោយ នាយឧត្តមសេនីយ៍ ប៉ោ ភក្តិ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ និងជាប្រធានក្រុមការងារឧក្រិដ្ឋកម្មឆ្លងដែនកម្ពុជាដោយមានការចូលរួមពី អនុប្រធាន សមាជិក នៃក្រុមការងារ SOMTC ព្រមទាំងមន្ត្រីបង្គោលទទួល ផែនការងារពាក់ព័ន្ធផងដែរ។ គោលបំណងសំខាន់ នៃកិច្ចប្រជុំគឺដើម្បីពិនិត្យការងារ ដែលបានអនុវត្តទៅលើផែនការមួយចំនួន ទាក់ទងនិងឧក្រិដ្ឋកម្មឆ្លងដែន និងពិនិត្យលើបច្ចុប្បន្នភាព និងដោះស្រាយទៅលើបញ្ហាប្រឈមថ្មីៗ ដែលទើបតែកើតមាន ឡើង។

- **ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ែន សិរីលក្ខិណា អគ្គលេខាធិការរង ទទួលបន្ទុកក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ និងអន្តរជាតិ និងជាប្រធានប្រតិភូកម្ពុជា សម្រាប់កិច្ចប្រជុំពិគ្រោះយោបល់ជាមួយដៃគូសន្ទនា អាស៊ាន និងកាណាដា លើកទី១០ ដឹកនាំដោយ ប្រទេសម៉ាឡេស៊ី តាមរយៈប្រព័ន្ធវីដេអូពីចម្ងាយ។ ក្នុងកិច្ចប្រជុំពិគ្រោះយោបល់ ជាមួយដៃគូសន្ទនារវាង SOMTC និងកាណាដា ក្នុងនាមលោកជំទាវ ជាប្រធានប្រតិភូ តំណាងកម្ពុជា ក៏បានលើកឡើងនូវចំនុចគោលមួយចំនួន ទាក់ទងនឹងការបង្កើតឯកសារសហប្រតិបត្តិការជាផ្លូវការ រវាងការអនុវត្តច្បាប់នៃប្រទេសកម្ពុជា និងកាណាដា ជាពិសេសរវាងកងកម្លាំងសមត្ថកិច្ច។ បច្ចុប្បន្នកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់របស់យើងភាគច្រើន សម្រេចបាន តែតាមរយៈទំនាក់ទំនង នៅក្នុងក្របខ័ណ្ឌ INTERPOL ក្នុងនោះដែរកាណាដា ក៏ជាម្ចាស់ជំនួយ ចំពោះអង្គការមួយចំនួនដែលបានធ្វើការងារពាក់ព័ន្ធនឹងការប្រយុទ្ធ ប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា ហើយក្នុងចំណោមអង្គការទាំងនោះ គឺមានមួយចំនួនដែលកំពុងមាន កិច្ចសហប្រតិបត្តិការល្អជាមួយ គ.ជ.ប.ជ ក្នុងការបំពេញ បេសកកម្ម

ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនេះ។ បើទោះបីជាមានការរីករាលដាលនៃជំងឺកូវីដ១៩ យ៉ាងណាក្តី ក៏នៅតែមានសកម្មភាពឧក្រិដ្ឋកម្មគួរឱ្យកត់សម្គាល់ មួយចំនួនកើនឡើងផងដែរ ជាពិសេសការ ជួញដូរគ្រឿងញៀន ការរត់ពន្ធមនុស្ស និងការជួញដូរមនុស្ស ឧក្រិដ្ឋកម្មតាមអ៊ិនធឺណិត និងឧក្រិដ្ឋកម្មពាក់ព័ន្ធ នឹងការលាងលុយជាដើម។ ដូច្នេះហើយក្នុងនាម SOMTC កម្ពុជា និងក្នុងស្មារតីនៃការបន្ត និងពង្រីក កិច្ចសហប្រតិបត្តិការរបស់យើងមួយកម្រិតទៀត ដោយផ្អែកលើយន្តការដែលមានស្រាប់ និងសូមស្វាគមន៍ ចំពោះឯកសារ សហប្រតិបត្តិការផ្លូវការស្តីពីវិស័យផលប្រយោជន៍ទៅវិញទៅមក ជាពិសេសឧក្រិដ្ឋកម្មឆ្លងដែន និងការកសាងសមត្ថភាព ក្នុងចំណោមអ្នកផ្សេងទៀត។

- **ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង ទទួលបន្ទុកក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ និងអន្តរជាតិ លោកស្រីវរសេនីយ៍ទោ ថោង សុវត្ថី អនុប្រធានក្រុមជំនួយកិច្ចការ បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំស្តីពី កាបែងចែកការងារកំណែឯកសារអប់រំផ្សព្វផ្សាយ និងការប្រព្រឹត្តទៅនៃវគ្គបណ្តុះបណ្តាលកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ដ។ អញ្ជើញចូលរួមមាន ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង ប្រធានក្រុមជំនួយកិច្ចការ អនុប្រធាន សមាសភាពជាគ្រូបង្គោល និងមន្ត្រីពាក់ព័ន្ធរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ដ ។

**ខ.២-ការងារចងក្រងព័ត៌មានតាមគេហទំព័រសារព័ត៌មាននានា** (មានឆ្លាប់ក្នុងឧបសម្ព័ន្ធ)

- <u>គ្រោះថ្នាក់ ឬហានិភ័យការងារក្នុងប្រទេសគោលដៅ</u>
  - ឧបទ្ទវហេតុ **០០ នាក់**
  - ពលករសរុប **០០ នាក់**
- <u>ប្រព្រឹត្តបទល្មើសនៅនឹងកន្លែង</u>
  - ចាប់ខ្លួន **០០ នាក់**
  - ពលករសរុប **០០ នាក់**
- <u>ពលកររួចទោសពីពន្ធនាគារ</u>
  - ពលករសរុប **០០ នាក់**
- <u>ពលករចំណាកស្រុកខុសច្បាប់</u>
  - បញ្ជូនត្រឡប់ **១២២នាក់**
  - ចាប់ខ្លួន **០០នាក់**
  - ពលករសរុប **១២២នាក់**

គ-ទិសដៅបន្ត

- បណ្តុះបណ្តាលជំនាញមូលដ្ឋានបច្ចេកទេសសរសេរប្រេូក្រាមដល់ក្រុមការងារព័ត៌មានវិទ្យាថ្មី

ថ្ងៃ ខែ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០២២

**ប្រធាន**

**ក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ និងអន្តរជាតិ**

**ចម្លងជូន៖**

-លេខាធិការដ្ឋានរដ្ឋបាលសរុប

-លោកជំទាវអគ្គលេខាធិការរងទទួលបន្ទុក

-លោកជំទាវអគ្គលេខាធិការ

"ដើម្បីជូនជ្រាប" ជាសេចក្តីរាយការណ៍

-ឯកសារ-កាលប្បវត្តិ